**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខៈ ១១៣០ សរណ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល លេខ ២៥៣១
ថ្ងៃទី ២៨.០៧-១១
បញ្ជូន

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែកក្កដាឆ្នាំ ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** : ករណីសំណើសុំគោលការណ៍អនុញ្ញាតផ្តល់ដីសម្បទានសេដ្ឋកិច្ចជូនក្រុមហ៊ុន ហៀប កុកហាំ ចំនួន ២៣៨.៥០ ហិកតា សម្រាប់វិនិយោគដាំដំណាំកសិឧស្សាហកម្ម ស្ថិតនៅក្នុងឃុំទីវង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

**យោង** : លិខិតលេខ ២១៣ ស.ណ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ របស់សាលាខេត្តកំពង់ធំ ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបឯកឧត្តមជ្រាបថា សាលាខេត្តកំពង់ធំបានធ្វើលិខិតមកក្រសួងមហាផ្ទៃ ស្នើសុំគោលការណ៍អនុញ្ញាតផ្តល់ដីសម្បទានសេដ្ឋកិច្ចជូនក្រុមហ៊ុន ហៀប កុកហាំ ចំនួន ២៣៨.៥០ហិកតា សម្រាប់វិនិយោគដាំដំណាំកសិឧស្សាហកម្ម ស្ថិតនៅក្នុងឃុំទីវង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដើម្បីលើកស្ទួយការវិនិយោគខ្នាតតូចនៅក្នុងខេត្តកំពង់ធំ ។ ដោយពិនិត្យឃើញថាសំណើសុំដីសម្បទានសេដ្ឋកិច្ចនេះស្ថិតក្នុងដែនសមត្ថកិច្ចជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃសូមបង្វែរសមត្ថកិច្ចក្នុងការដោះស្រាយជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និងបន្តចាត់ចែងតាមសមត្ថកិច្ច តាមការគួរ ។

សូមឯកឧត្តម ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

**ស ខេង**

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ធំ
- ឯកសារ កាលប្បវត្តិ